ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

រាជធានីភ្នំពេញ, ថ្ងៃទី...០១...ខែកញ្ញា ឆ្នាំ ២០០៧

លេខៈ...១៩៥...ប្រក

# ប្រកាស

## ស្តីពី

## តួនាទីភារកិច្ចនិងរចនាសម្ព័ន្ធ
## របស់នាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌

## រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /០៧០៤ /១២៤ /ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលបានប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស /រកម / ០១៩៦ /០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ ២៤អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- យោងតាមការងារចាំបាច់របស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

## ស ម្រេ ច

**ប្រការ ១ .-**

នាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌ ជាអង្គភាពថ្នាក់កណ្តាល ស្ថិតនៅក្រោមឱវាទអគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មានសមត្ថកិច្ចដឹកនាំសកម្មភាពវប្បធម៌ ទាំងនៅថ្នាក់កណ្តាល តាមភូមិភាគនិងតំបន់ ដោយសហការយ៉ាងជិតស្និទ្ធ ជាមួយនាយកដ្ឋាននានា ក្នុង ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ជាមួយក្រសួងផ្សេង ១ ទៀត

និងជាមួយអាជ្ញាធរ ដែនដី ដែលពាក់ពន្ធ័ក្នុងតួនាទីបំផុសសម្របសម្រួលនយោបាយអភិវឌ្ឍន៍វប្បធម៌ដែលស្ថិតក្នុងសមត្ថកិច្ច ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

- នាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌ មានអក្សរកាត់ << ន.អ.ភិ.វ.>> ។

**ប្រការ ២ . ~**

នាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌ មានភារៈកិច្ច ដូចតទៅ :-

- លើកទឹកចិត្តរាល់សកម្មភាពវប្បធម៌ ទាំងរៀបចំចាត់តាំងបណ្តាការសម្តែងសិល្បៈវប្បធម៌ ពិព័រណ៍សំដៅធ្វើឱ្យមហាជនចាប់អារម្មណ៍និងវប្បធម៌របស់ខ្លួន
- បំផុសនិងសម្រួលដល់សមាគមវិជ្ជាជីវៈផ្សេងៗក្នុងវិស័យវប្បធម៌សំដៅលើកកម្ពស់មនសិការវិជ្ជាជីវៈព្រមទាំងការពារផលប្រយោជន៍ស្របច្បាប់របស់គេ
- លើកទឹកចិត្តនិងត្រួតពិនិត្យចំពោះការថែរក្សារាល់សកម្មភាពវប្បធម៌ល្អៗរបស់ប្រជាពលរដ្ឋ តាមតំបន់ទូទាំងប្រទេស
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន
- ទទួលអនុវត្តភារៈកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន ។
- នាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌ ដឹកនាំដោយប្រធានមួយរូប និង អនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

**ប្រការ ៣ . ~**

នាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌ មានរចនាសម្ព័ន្ធដូចខាងក្រោម -:

១ - ការិយាល័យ រដ្ឋបាលទូទៅ

២ - ការិយាល័យ សកម្មភាពវប្បធម៌ និង ពិព័រណ៍

៣ - ការិយាល័យ អប់រំវប្បធម៌ និងពិធីបុណ្យប្រពៃណី

៤ - ការិយាល័យ សមាគម និងសហគមន៍ជនបទ

៥ - ការិយាល័យ វប្បធម៌ជនជាតិ

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ អង្គការលេខរបស់នាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌ ជាឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ ៤ . ~**

ភារកិច្ចការិយាល័យនីមួយៗ :

ក- <u>ការិយាល័យរដ្ឋបាល</u>

- ទទួលការងាររបៀប
- ធ្វើលិខិតផ្សេងៗ និង រក្សាទុកឯកសារ
- លើកទិសដៅ និងកម្មវិធីការងារ សរុបសកម្មភាពការងារក្នុងនាយកដ្ឋាន ធ្វើរបាយការណ៍ បូកសរុបប្រចាំ

សប្តាហ៍ ខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ

- សម្របសម្រួល ការងារបុគ្គលិក និងសំណូមពរពីគ្រប់ការិយាល័យ
- ស្ថាបនាផែនការស្ថិតិ និងកម្មវិធីការងារប្រចាំឆ្នាំ ឆមាស ត្រីមាស និងប្រចាំខែ
- ធ្វើតារាងបៀវត្ស ជូនមន្ត្រីរាជការ
- គ្រប់គ្រងសម្ភារៈបរិក្ខារការិយាល័យ និងបញ្ជីសារពើភណ្ឌចលនៈនិងអចលនៈទ្រព្យ ក្នុងនាយកដ្ឋាន
- រក្សាទុកដាក់ត្រារបស់នាយកដ្ឋាន
- ធានាប្រក្រតីភាពកិច្ចការរដ្ឋបាលសណ្តាប់ធ្នាប់ និងពង្រឹងការអនុវត្តន៍បទបញ្ជាផ្ទៃក្នុងរបស់នាយកដ្ឋាន
- ជំរុញ និងតាមដានពិនិត្យសកម្មភាពការងារ គ្រប់ការិយាល័យ ក្នុងនាយកដ្ឋាន
- អនុវត្តភារកិច្ចផ្សេងៗដែលនាយកដ្ឋានប្រគល់ជូន ។

ខ- ការិយាល័យសកម្មភាពវប្បធម៌ និងពិព័រណ៍

- សិក្សាស្រាវជ្រាវចងក្រងឯកសារ និងលើកកម្មវិធីសំរាប់ធ្វើសកម្មភាពវប្បធម៌និង ពិព័រណ៍
- គ្រប់គ្រងនិងលើកគំរោងកម្មវិធីតុបតែងរៀបចំពិធីបុណ្យជាតិ និងពិធីបុណ្យប្រពៃណីផ្សេងៗ
- បោះពុម្ពរូបបណ្ណ័ផ្សេងៗ ដើម្បីផ្សព្វផ្សាយវប្បធម៌
- លើកកម្មវិធីសំរាប់ផ្សព្វផ្សាយ និងអប់រំតាមរយៈការតាំងពិព័រណ៍
- រៀបចំការប្រលងប្រជែងលើវិស័យវប្បធម៌ និងវិចិត្រសិល្បៈ
- រៀបចំពិធីបុណ្យនានាដែលជាប្រពៃណី ទំនៀមទំលាប់ ដើម្បីស្តារនិងពង្រីកវិស័យសិល្បៈវប្បធម៌ និងដើម្បីបំរើការកំសាន្តរបស់សាធារណៈជនផង
- ជំរុញឱ្យមានសកម្មភាពវប្បធម៌ និងការប្រារព្ធរាល់ពិធីបុណ្យប្រពៃណីទូទាំងប្រទេស
- រៀបចំតាំងពិព័រណ៍សមិទ្ធិផល សង្គមជាតិ ពិព័រណ៍វប្បធម៌ ពាណិជ្ជកម្ម
- រៀបចំ និងគ្រប់គ្រង់ មជ្ឈមណ្ឌលវប្បធម៌ជាតិ មជ្ឈមណ្ឌលវប្បធម៌ មណ្ឌលវប្បធម៌ អាគារវប្បធម៌ ភូមិវប្បធម៌ ក្រុមវប្បធម៌ ។

គ- ការិយាល័យអប់រំវប្បធម៌ និងពិធីបុណ្យប្រពៃណី

- ស្រង់ឯកសារសំរាប់រៀបចំកម្មវិធីសកម្មភាពវប្បធម៌ និងបុណ្យប្រពៃណីជាតិ
- សិក្សាស្រាវជ្រាវចងក្រងឯកសារស្តីពីសិល្បៈវប្បធម៌ ទំនៀមទំលាប់ និងជំនឿរបស់ខ្មែរ
- រៀបចំកម្មវិធីអប់រំសិល្បៈវប្បធម៌ទូទៅ បញ្ចូលទៅក្នុងកម្មវិធីសាលាចំណេះទូទៅ ដោយ សហការ ជាមួយ ក្រសួងអប់រំយុវជន និងកីឡា
- ផ្សព្វផ្សាយអប់រំ លើកកម្ពស់ពង្រីកវប្បធម៌ ទំនៀមទំលាប់ប្រពៃណីខ្មែរ និងទប់ស្កាត់ការបំផ្លិចបំផ្លាញវប្បធម៌ ទំនៀមទំលាប់ប្រពៃណីតាមរយៈការបិទ បោះ ផ្សាយ និង ពិធីបុណ្យ
- ជំរុញ និងពង្រីកការច្នៃប្រឌិតនូវសម្ភារៈប្រើប្រាស់ដោយផ្អែកតាម ទំនៀមទំលាប់ខ្មែរ

- បង្កលក្ខណៈរាល់វិស័យវប្បធម៌ ឱ្យចូលរួមក្នុងវិស័យសេដ្ឋកិច្ច
- គ្រប់គ្រងល្បែងប្រជាប្រិយ៍របស់មហាជន និងប្រជាជនខ្មែរ ។

ឃ- ការិយាល័យសមាគម និង សហគមន៍ជនបទ

- សិក្សាស្រាវជ្រាវចងក្រង សមាគម សហគមន៍ជនបទ ដើម្បីលើកកម្ពស់ពង្រីកសកម្មភាព វប្បធម៌ល្អប្រ ផ្សព្វផ្សាយក្នុងសង្គម
- ណែនាំជំរុញឱ្យមានការបង្កើតជាសមាគម ក្លឹប ក្រុម ដែលធ្វើសកម្មភាព ក្នុងវិស័យវប្បធម៌ទូទាំងប្រទេស
- គ្រប់គ្រងសម្របសម្រួល និងសហការជាមួយអង្គការសង្គមស៊ីវិលទាក់ទងនិងវិស័យវប្បធម៌ និងវិចិត្រសិល្បៈ លើកកម្ពស់សកម្មភាពវប្បធម៌ឱ្យបានទូលំទូលាយក្នុងស្រទាប់ប្រជាជន
- គាំទ្រលើកទឹកចិត្តសកម្មភាពរបស់អង្គការ ក្រៅរដ្ឋាភិបាល-សមាគម-ក្លឹប-ក្រុមដែលធ្វើសកម្មភាពស្របតា គោលនយោបាយរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ធ្វើការសិក្សាស្រាវជ្រាវដើម្បីចងក្រងឱ្យមានសហគមន៍វប្បធម៌នៅតាមជនបទ ខេត្ត-ក្រុង ទូទាំងប្រទេសក្នុង គោលនយោបាយអភិរក្ស និង អភិវឌ្ឍន៍សហគមន៍ក្នុងសង្គមដើម្បី រក្សាបាននូវ អត្តសញ្ញាណវប្បធម៌ប្រចាំ តំបន់ឬ សហគមន៍នីមួយៗ
- បង្កើតឱ្យមានក្រុមអប់រំចល័ត ដើម្បីធ្វើការអប់រំផ្សព្វផ្សាយនូវគោលនយោបាយ ដើម្ប លើកកម្ពស់តម្លៃ ពីវប្បធម៌ជាតិតាមបណ្តាសហគមន៍ជនបទទូទាំងប្រទេស
- ធ្វើរបាយការណ៍អំពីស្ថានភាពវប្បធម៌ក្នុងសង្គម ដើម្បីមានវិធានការទប់ស្កាត់រាល់ បាតុភាពអសកម្ម ។

ង- ការិយាល័យវប្បធម៌ជនជាតិ

- សិក្សាស្រាវជ្រាវគ្រប់ វិស័យវប្បធម៌ជនជាតិ ដើម្បីផ្សព្វផ្សាយអប់រំសម្របសម្រួលរាល់សកម្ម ភាពវប្បធម៌ ជនជាតិ ក្នុងគោលបំណងលើកតម្កើងនូវវប្បធម៌ ទំនៀមទំលាប់ ប្រពៃណីល្អប្រសើររបស់ពួកគេ
- ប្រមូលនិងចងក្រងឯកសារស្តីពីសិល្បៈវប្បធម៌ទំនៀមទំលាប់ជំនឿ និងជីវភាពរស់នៅរបស់ ជនជាតិ ដើមភាគ
- ជំរុញសកម្មភាពវប្បធម៌ជនជាតិតាមតំបន់នីមួយៗ ដើម្បីស្វែងយល់អំពីជីវភាពរស់នៅ របស់ពួកគេ ឱ្យសម ក្នុងសង្គមជាតិ
- ជំរុញការស្តារនិងអភិរក្ស ដើម្បីអភិវឌ្ឍន៍ អត្តសញ្ញាណវប្បធម៌ជនជាតិដើមភាគតិច និមួយៗក្នុងតំបន់។

**ប្រការ ៥ . ~**

ប្រកាស និងបទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនិងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៦ .**

នាយកខុទ្ទការល័យ អគ្គនាយក នៃអគ្គនាយកដ្ឋាន រដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយក នៃអគ្គនាយកដ្ឋាន បច្ចេកទេសវប្បធម៌ អគ្គនាយក នៃអគ្គនាយកដ្ឋានបេតិកភណ្ឌ ប្រធាននាយកដ្ឋាន អភិវឌ្ឍន៍វប្បធម៌ ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត – ក្រុង និងអង្គភាពពាក់ពន្ធ័ត្រូវទទួល បន្ទុកអនុវត្តន៍ប្រកាសនេះ តាមភារៈកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ចម្លងជូន**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- ដូចប្រការ ៦" ដើម្បីអនុវត្តន៍"
- ឯកសារ- កាលប្បវត្តិ

រដ្ឋមន្ត្រី

អ៊ឹម ឆែម

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
នាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌

ឧបសម្ព័ន្ធនៃប្រកាសលេខ ១៨៩ ប្រក ថ្ងៃទី ៣.......ខែ កក្កដា ឆ្នាំ២០០៧
អង្គភាពលេខបស់នាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌

